# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ**

ថ្ងៃព្រហស្បតិ៍ ៨រោច ខែបឋមាសាឍ ឆ្នាំ ច សំរឹទ្ធិស័ក ២៥៦២

ខេត្តព្រះសីហនុ, ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១៨

## សេចក្តីប្រកាសព័ត៌មាន
## ស្តីពី លទ្ធផលកិច្ចប្រជុំក្រុមប្រឹក្សាភិបាល អាណត្តិទី៧ លើកទី១
## របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ
## ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៨

កំពង់ផែស្វយ័តក្រុងព្រះសីហនុ (**កសស**) សូមជម្រាបជូនវិនិយោគិន និងសាធារណជនមេត្តាជ្រាបថា៖ **នៅថ្ងៃទី ០៣ ខែកក្កដា ឆ្នាំ២០១៨ វេលាម៉ោង ១៤:៣០ ឯកឧត្តម លូ គឹមឈន់** ប្រធានក្រុមប្រឹក្សាភិបាលនៃ **កសស** បានអញ្ជើញចូលរួមជាអធិបតីដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាភិបាល អាណត្តិទី៧ លើកទី១ នៅសាលប្រជុំទីស្តីការក្រសួងពាណិជ្ជកម្ម ។

នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលនេះ បានប្រកាស ពិនិត្យ និងសម្រេចលើរបៀបវារៈ ដូចខាងក្រោម ៖

១. យោងតាមអនុក្រឹត្យលេខ៦០៨ អនក្រ.តត ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨ ក្រុមប្រឹក្សាភិបាលបានប្រកាសស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលកំពង់ផែស្វយ័តក្រុងព្រះសីហនុ សម្រាប់អាណត្តិទី៧ ។

២. ពិនិត្យ និង ឯកភាពលើរបាយការណ៍ការងារអាជីវកម្ម **កសស** ០៦ខែ ឆ្នាំ២០១៨ ។

៣. ពិនិត្យ និងអនុម័តលើការបែងចែកភាគលាភជូនភាគហ៊ុនិកសម្រាប់ការិយបរិច្ឆេទ ២០១៧ ។

៤. ឯកភាពលើការមិនទទួលយកលាភការរបស់លោក **Hidetoshi KUME** ប៉ុន្តែ **កសស** ត្រូវផ្តល់ការចំណាយសម្រាប់ការធ្វើដំណើរ ស្នាក់នៅ របស់លោក **Hidetoshi KUME** ក្នុងពេលចូលរួមកិច្ចប្រជុំ **កសស** ម្តងៗ ដែលយោងតាមអនុក្រឹត្យលេខ ២១៦អនក្រ.បក ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០១៤។

៥. ក្រុមប្រឹក្សាភិបាល សម្រេចនិងអនុញ្ញាតឲ្យប្រធានក្រុមប្រឹក្សាភិបាលអាចប្រើប្រាស់ត្រាកំពង់ផែស្វយ័តក្រុងព្រះសីហនុ ។

អង្គប្រជុំក្រុមប្រឹក្សាភិបាលបានបញ្ចប់នៅវេលាម៉ោង ១៨:១៥ នាទី នាថ្ងៃ ខែ និងឆ្នាំដដែល ប្រកបដោយបរិយាកាសស្និទ្ធស្នាល និងយកចិត្តទុកដាក់ខ្ពស់ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមវិនិយោគិន និងសាធារណជនទទួលជ្រាបជាព័ត៌មាន ។

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ**


តិរវិថី សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
Tarak Vithei Samdech Akka Moha Sena Padei Techo HUN SEN
Sangkat N°3, Preah Sihanouk City, Preah Sihanouk Province
Office : 034 933 416; 034 933 511 Pilot : 034 933 507; Fax : 034 933 693
E-mail : pasinfo@pas.gov.kh; spsez@pas.gov.kh
Website: www.pas.gov.kh